**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ស្ថានឯកអគ្គរាជទូតកម្ពុជា

ប្រចាំសាធារណរដ្ឋកូរ៉េ

លេខ: ៣២០.០៩ សកស

សេអ៊ូល, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៩

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**និងជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** កម្មវិធីទស្សនកិច្ចសិក្សានៅតំបន់ឧស្សាហកម្ម នៃសាធារណរដ្ឋកូរ៉េ

**យោង:** លិខិតលេខ: AKC/TI/LT/2 របស់មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ ចុះថ្ងៃទី ៣០.០៦.០៩ " ជូនភ្ជាប់ "

ខ្ញុំបាទមានកិត្តិយសសូមជំរាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ បានជូនពតិមានស្តីពី **ការអនុវត្តគម្រោងកម្មវិធីការងារវិនិយោគ ២០០៩** Investment Work Program for Fiscal Year 2009 រវាងសាធារណរដ្ឋកូរ៉េ និងបណ្តាប្រទេសសមាជិកអាស៊ាន ដែលក្នុងនោះរួមមាន កម្មវិធី **ទស្សនកិច្ចសិក្សានៅតំបន់ឧស្សាហកម្ម** Industrial Familiarization Program ។

**កម្មវិធីទស្សនកិច្ចសិក្សានៅតំបន់ឧស្សាហកម្ម** Industrial Familiarization Program

**អញ្ជើញ** : មន្ត្រីរដ្ឋាភិបាល និងវិស័យឯកជន នៃប្រទេសនីមួយៗ ចំនួន៤ រូប

**កាលបរិច្ឆេទ** : ចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០៩

**ការងារ** : ជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាលកូរ៉េ សមាគមពាណិជ្ជករកូរ៉េ ទស្សនកិច្ចតំបន់ឧស្សាហកម្ម

**រយៈពេលស្នាក់នៅកូរ៉េ** : ៣យប់ និង៤ថ្ងៃ

**មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ ទទួលបន្ទុក: សំបុត្រយន្តហោះ ធានារ៉ាប់រងការធ្វើដំណើរ ការស្នាក់នៅ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ព្រមទាំងការចំណាយផ្សេងៗទៀតដែលជាតម្រូវការ ។**

**កំណត់ចំណាំ** : លេខាធិការដ្ឋាននៃមជ្ឈមណ្ឌលអាស៊ាន-កូរ៉េ រង់ចាំទទួលចម្លើយ អំពីការចូលរួមរបស់ភាគីកម្ពុជាក្នុងកម្មវិធី ដែលបានជំរាបជូនខាងលើ ។

សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបនិងពិនិត្យសម្រេច ដ៏ខ្ពង់ខ្ពស់ ។

សូម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរព ដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំបាទ ។

**ចម្លងជូន** :
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងពាណិជ្ជកម្ម

" ដើម្បីជូនជ្រាប "
- ឯកសារ-កាលប្បវត្តិ

**ឯកអគ្គរាជទូត**

**លឹម សំគុល**

Royal Embassy of Cambodia
653-110 Hannam-dong
Yongsan-gu, Seoul 140-887
Republic of korea

Tel 82 2 3785 1041
Fax : 82 2 3785 1040
E-mail : camboemb@korea.com

ASEAN-KOREA CENTRE
Secretary General

AKC/TI/LT/2
30 June 2009

H.E. Lim Samkol
Ambassador
Embassy of Cambodia
653-110, Hannam-dong, Yongsan-gu
Seoul

Your Excellency,

I wish to refer to the Industrial Familiarization Program (IFP), one of the ASEAN-Korea Centre's "Investment Work Programs for Fiscal Year 2009," which were approved at the Inaugural Council Meeting on 13 March 2009.

The IFP aims to update ASEAN government officials and private sector representatives on the latest trends and developments in Korean government investment policies, and the needs of potential Korean investors, and Korean business environment in selected industries.

In this regard, the ASEAN-Korea Centre is pleased to invite government officials and private sector representatives (4 persons in total) from each ASEAN Member Country for the IFP, scheduled to take place during 6-9 October 2009 (3 nights and 4 days) in Seoul, Korea. The Program will include meetings with Korean government officials and business associations, and visits to industrial sites, etc.

The ASEAN-Korea Centre will pay for participants' airfare, accommodation, daily travel allowance, and other related costs where required.

The Secretariat would be grateful if your Embassy would forward this proposal to your government, and let me know whether your government officials and private sector representatives will be able to participate in the program as proposed.

If you have any questions, please don't hesitate to contact the Centre' Secretariat (Trade & Investment Unit).

Best Regards,

CHO, Young-Jai
Secretary-General